

# ព្រះពាយ និងព្រះអាទិត្យ

Let's Read

The Asia Foundation

ដោយសារអ្នកនិពន្ធ វិចិត្រករ និងអ្នកបោះពុម្ពសៀវភៅនេះ គាំទ្រលើកទឹកចិត្តឲ្យយកស្នាដៃនេះទៅបកប្រែជាភាសាផ្សេងៗ ពួកគាត់សំណូមពរថារាល់ការកែប្រែផ្នែកសំខាន់ សូមរក្សាយ៉ាងណាកុំឲ្យប្រាសចាកឆ្ងាយពីទម្រង់អត្ថបទ និងរូបភាពដើម។



សម័យថ្ងៃមួយ ព្រះពាយ និងព្រះអាទិត្យ បានអួតពីឫទ្ធិអំណាចរៀងៗខ្លួន។



ព្រះពាយ បានពោលដោយអំនួតថា ”យើងធ្លាប់រម្លើងដើមឈើ ធំៗ និងពន្លិចនាវាអស់រាប់លានឯណោះ។ ឯងមិនអាចធ្វើដូច្នេះ បានដូចយើងឡើយ។”



ព្រះអាទិត្យ ញញឹម ហើយតបធ្វើហី ”គ្រាន់តែប៉ុណ្ណឹងមិនអាច បញ្ជាក់ថា ឯងខ្លាំងជាងយើងនោះទេ។”



ព្រះពាយ តបវិញថា ”យើងអាចឲ្យពពកបាំងឯងឲ្យជិត ពេលនោះអ្នកណាក៏មើលឯងមិនឃើញដែរ! ប៉ុន្តែឯងវិញ មិនអាចធ្វើដូច្នេះដាក់យើងបានឡើយ។”



ព្រះអាទិត្យ ញញឹមតិចៗ រួចតបតាមសម្រួលថា "យើងនៅតែគិតថា យើងខ្លាំងជាងឯង។"



ព្រះពាយ ក៏ចាប់ផ្ដើមសម្ដែងការមិនពេញចិត្ត ពេលឮថា ព្រះអាទិត្យខ្លាំងជាងខ្លួន។ ព្រះពាយក៏លើកយោបល់ថា ” បើដូច្នេះ យើងត្រូវតែសាកល្បងគ្នាទើបបាន។”



ព្រះពាយក្រឡេកមើលជុំវិញដើម្បីរកមធ្យោបាយបង្ហាញអានុភាពរបស់ខ្លួន។ ព្រះពាយសួរទៅកាន់ព្រះអាទិត្យថា ”ឥឡូវចាំមើលថា តើអ្នកណាអាចរំលំផ្ទះទាំងនោះឲ្យដួលរាបដល់ដីបានច្រើនជាងគេ?”



ព្រះអាទិត្យក៏តបថា ”មិនចាំបាច់ដល់ថ្នាក់នោះទេ ធ្វើបែប សាមញ្ញទៅបានហើយ។ តើឯងឃើញបុរសនោះទេ?” ព្រះពាយស្ដាប់ហើយក្រឡេកមើលទៅ ឃើញបុរសម្នាក់កំពុងដើរតាមផ្លូវ។ គាត់បង់កក្រមា ដើរហួចម្នាក់ឯងយ៉ាងរីករាយ។



ព្រះពាយពោលថា ”ចាំមើលអ្នកណាអាចធ្វើឲ្យគាត់បើុងចេញពីផ្លូវនេះបានមុនគេ?” ព្រះអាទិត្យក៏តបវិញថា ”ទេ បែបនេះបានត្រឹឹមតែធ្វើឲ្យគាត់មានគ្រោះថ្នាក់ប៉ុណ្ណោះ។ ឥឡូវគ្រាន់តែភ្នាល់ថា អ្នកណាអាចធ្វើឲ្យគាត់ដោះក្រមាបង់កចេញទៅបានហើយ។”



ព្រះពាយ យល់ព្រម រួចក៏រសាត់ទៅផ្តុំលើអាកាស។ បន្ទាប់មក ព្រះពាយ ក៏ក្តួចបោកបក់យ៉ាងវក់វីធ្វើឲ្យប៉ើងជ្រុះស្លឹកឈើពីដើម។ បុរសជ្រួញចិញ្ចើមសម្លឹងមើលទៅលើមេឃ ហើយប្រឹងក្តោបកន្សែងបង់កររបស់ខ្លួនយ៉ាងជាប់។



រំពេចនោះពពកខ្មៅលាយឡំនឹងផ្គររន្ទះលេចឡើងពាសពេញមេឃ។ សត្វនានាចាប់ផ្តើមរត់រកទីជម្រក ឯព្រះពាយ ក៏ចាប់ផ្តើមគ្រហឹម។ បុរសនោះកាន់តែក្តោបក្រមាបង់កជាប់ជាងមុន។



មិនយូរប៉ុន្មានផ្គររន្ទះបានស្ងប់ទៅវិញ។ ព្រះពាយ ប្រឹងផ្លុំឡើង អស់កម្លាំងពីខ្លួន។ ព្រះពាយ ដង្ហក់ដកដង្ហើមស្ទើរមិនដល់គ្នា។ ”ខ្ញុំសុំចុះចាញ់ហើយ។ ខ្ញុំទៅលែងរួចហើយ។” ពោលរួច ព្រះពាយ ក៏ក្ដួចឡើងទៅសម្រាកលើពពក។



ព្រះអាទិត្យ ក៏ពោលឡើងថា "ឥឡូវដល់វេនខ្ញុំហើយ!" ពោលរួច ព្រះអាទិត្យក៏ស្វាបពត់ខ្លួនបញ្ចេញពន្លឺយ៉ាងរំភើយ។ ព្រះអាទិត្យ បញ្ចេញពន្លឺលើអាកាសកាន់តែខ្លាំងឡើងៗ។ មិនយូរប៉ុន្មាន អាកាសធាតុក៏ប្រែជាក្តៅហាក់ដូចជានៅរដូវក្តៅ។



បុរសនោះ សម្លឹងទៅលើមេឃ រួចជូតញើសចេញពីថ្ងាសរបស់គាត់។



គាត់និយាយរអ៊ូតែម្នាក់ឯងថា ”អាកាសធាតុអីក៏ចម្លែកម្ល៉េះ ថ្ងៃនេះ!”



បន្ទាប់មក គាត់ក៏ដោះក្រមាបង់កយកមកត្បៀតភ្លៀក។



ព្រះពាយ ទះដៃធ្វើឲ្យស្លឹកឈើរង្គើររិចៗ។



ព្រះអាទិត្យ ញញឹមតបដោយចំអន់លេងថា ”ឯងមិនចាំបាច់ប្រើ
កម្លាំងបាយបង្ខំឲ្យគាត់ដោះក្រមាបង់កចេញនោះទេ។”



ព្រះពាយ និងព្រះអាទិត្យ សើចជាមួយគ្នា ហើយតាមមើលបុរស
នោះដើរហួចម្នាក់ឯងតាមផ្លូវម្ដងទៀតយ៉ាងរីករាយ។

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*The Wind and the Sun*, Published by BookBox, © BookBox.
Released under CC BY-NC-SA 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY-NC-SA 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc-sa/4.0/
Contributing translators: Chou Chinith